ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែ តុលា ឆ្នាំ ២០១០



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ និងសេចក្តីព្រាងអនុក្រឹត្យស្តីពី រូបសញ្ញា និងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ | ២ |
| ៣- | សេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម | ៣ - ៤ |
| ៤- | សេចក្តីព្រាងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ | ៥ |
| ៥- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ មជ្ឈមណ្ឌលមាត្រាសាស្ត្រ | ៦ |
| ៦- | កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតកាយរឹទ្ធិជាតិកម្ពុជា និងសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធិជាតិកម្ពុជា | ៧ |
| ៧- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១០ | ៨ - ១២ |
| ៨- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ - ១៧ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ របស់អង្គភាពប្រឆាំងអំពើពុករលួយ



កាលពីថ្ងៃទី២៩ ខែកញ្ញា និងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **អ៊ុំ ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ឱម យ៉ិនទៀង** ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់រដ្ឋ របស់រាជរដ្ឋាភិបាល ដើម្បីឱ្យមានអភិបាលកិច្ចល្អ ពង្រឹងនីតិរដ្ឋ អភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រ។ ទោះបីជាក្នុងដំណាក់កាល ដែលពុំទាន់មានច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមួយដោយឡែកក៏ដោយ ក៏រាជរដ្ឋាភិបាលបានចាត់វិធានការសំខាន់ៗ មួយចំនួនដែលមាននៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន ហើយកម្មវិធីនេះត្រូវបានអនុវត្តជាបន្តបន្ទាប់ ដោយបានបង្កើតយន្តការក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាអាទិ៍ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ដោយផ្តោតលើកត្តាជាសារវ័ន្តចំនួន៣ ដែលមានភាពប្រទាក់ក្រឡាគ្នា គឺ១-ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ ២-ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ៣-ការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

យោងតាមខ្លឹមសារនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវមានអនុក្រឹត្យមួយចំនួនដើម្បីអនុវត្តច្បាប់នេះ ក្នុងនោះអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជាតម្រូវការបន្ទាន់ដើម្បីឱ្យអង្គភាពនេះមានរចនាសម្ព័ន្ធរឹងមាំ និងដំណើរការងាររបស់ខ្លួនបាន (១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងយកចិត្តទុកដាក់ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើនសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## និងសេចក្តីព្រាងអនុក្រឹត្យស្តីពី

# រូបសញ្ញា និងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ និង សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរូបសញ្ញា និងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ឱម យ៉ិនទៀង** ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ សមាជិក និង អគ្គលេខាធិការរងនៃ ក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា បានយកចិត្តទុកដាក់ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់ខ្លួនឱ្យមានប្រសិទ្ធភាព តាមរយៈការបង្កើតយន្តការជាច្រើន ដែលនៅក្នុងនោះក៏មានស្ថាប័នប្រឆាំង អំពើពុករលួយផងដែរ។

យោងតាមមាត្រា១៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវមានថវិកា និងធនធានដោយឡែកសម្រាប់ដំណើរការងារ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ហេតុនេះ ការរៀបចំអនុក្រឹត្យនេះ ធ្វើឡើងក្នុងគោលបំណងបង្កើតឱ្យមានកញ្ចប់ថវិកា និងធនធានចាំបាច់នានា ដើម្បីជានាការប្រើប្រាស់ក្នុងការបំពេញការងារដែលរាជរដ្ឋាភិបាលប្រគល់ជូន។

យោងតាមមាត្រា ៥នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវមានរូបសញ្ញា និងត្រាដោយឡែក ដើម្បីដំណើរការងារ។ ការងារនេះ ក៏ត្រូវកំណត់ដោយអនុក្រឹត្យដែរ(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យទាំងពីរនេះយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលទម្រង់ ពាក្យពេចន៍ ឃ្លាប្រយោគ និងសម្រេចទុកបញ្ហាប្រាក់បំណាច់ និងប្រាក់ បន្ទាប់បន្សំទៅពិភាក្សាក្នុងពេលប្រជុំអន្តរក្រសួង ព្រោះមានសមាសភាពក្រសួងពាក់ព័ន្ធចូលរួម។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។

## សេចក្តីព្រាងច្បាប់ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

កាលពីថ្ងៃទី១២ ទី១៤ ទី២០ ទី២១ និងទី២៦ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង លោកជំទាវ **លី វ៉ួចឡេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងពាណិជ្ជកម្ម សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងពាណិជ្ជកម្មបានរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ដែលមានគោលដៅបង្កើតវិធានពិសេស នៃកិច្ចសន្យាពាណិជ្ជកម្ម និងមានគោលបំណងអភិវឌ្ឍនិង បង្កភាពងាយស្រួលក្នុងការទំនាក់ទំនងពាណិជ្ជកម្ម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សារៈសំខាន់នៃសេចក្តីព្រាងច្បាប់នេះ គឺគូភាគីនៃកិច្ចសន្យា តុលាការពាណិជ្ជកម្ម តុលាការរដ្ឋប្បវេណី ឬវេទិកាមជ្ឈត្តកម្ម មានភាពងាយស្រួលក្នុងការអនុវត្តកិច្ចសន្យាពាណិជ្ជកម្ម ដូចដែលមានចែងក្នុងសេចក្តីព្រាងច្បាប់តុលាការពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ម៉្យាងទៀត ច្បាប់នេះត្រូវបានរៀបចំឡើងដើម្បីបំពេញការខ្វះខាតនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

សេចក្តីព្រាងច្បាប់នេះមានលក្ខណៈពិសេសគឺ អនុវត្តចំពោះកិច្ចសន្យាដែលបង្កើតឡើងរវាងពាណិជ្ជករជាមួយនឹងពាណិជ្ជករ ឬរវាងពាណិជ្ជករជាមួយបុគ្គលមិនមែនជាពាណិជ្ជករ ដែលបានចែងនៅក្នុងកិច្ចសន្យាពិសេស ដូចជាកិច្ចសន្យាអាផ្ញាបណ្ណ ភតិសន្យាលើចលនទ្រព្យ ឬកិច្ចសន្យាសហគ្រាសនិងសេវា ដែលភាគីមានទំនាក់ទំនងពាណិជ្ជកម្មពិសេសនេះត្រូវបានទទួល ការការពារដូចគ្នានឹងពាណិជ្ជករដែរ(១) ។





គួររំឭកថា សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មនេះ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ម្តងហើយ។ អង្គប្រជុំនាពេលនោះ បានសម្រេចលើកពេល ដើម្បីឱ្យក្រុមការងារបង្កៀតប្រជុំជាមួយតំណាងក្រសួងក្នុងការរៀបចំសេចក្តីព្រាងនេះឡើងវិញ។ ក្រោយមក អង្គប្រជុំជំនាញបច្ចេកទេសធ្វើការប្រជុំបន្ត ហើយគិតត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះយ៉ាងប្រយ័ត្នប្រយែង ព្រោះច្បាប់នេះជាច្បាប់ពិសេស ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ និងរក្សាទុកចំណុចខ្លះ បន្តពិភាក្សានៅពេលប្រជុំអន្តរក្រសួង។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅមាត្រា៥៧ លើចនួនសរុប ២២៩មាត្រា៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម។

# សេចក្តីព្រាងយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ



កាលពីថ្ងៃទី១២ និងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម អេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ សមាជិក និងអគ្គលេខាធិការរង នៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ បានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដែលមានគោលបំណងកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃ និងអសន្តិសុខស្បៀងទ្រទ្រង់ដល់ជនក្រីក្រក្នុងការដោះស្រាយវិបត្តិ និងកសាងមូលធនមនុស្សសម្រាប់ពេលអនាគត ដើម្បីលុបបំបាត់វដ្តនៃភាពក្រីក្រ។ យុទ្ធសាស្ត្រជាតិនេះមានគោលបំណងចំបងៗចំនួន ៥ ដូចខាងក្រោម៖

១-ជនក្រីក្រ និងងាយរងគ្រោះ ទទួលបានការគាំទ្រ ដែលរួមមាន៖ ស្បៀង អនាម័យ ទឹក និងជម្រក។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ ក្នុងពេលវេលាមានគ្រោះអាសន្ននិងវិបត្តិ។

២-ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើតគុណភាពអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសពលកម្មដែលមានទម្រង់ធ្ងន់ធ្ងរ។

៣-ជនក្រីក្រ និងងាយរងគ្រោះ ដែលពេញវ័យធ្វើការងារ ទទួលបានផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឱ្យមានប្រាក់ចំណូល ស្បៀង និងមានការងារធ្វើ ព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គម ដែលមាននិរន្តរភាព។

៤-ជនក្រីក្រ និងងាយរងគ្រោះ ដោយមានប្រសិទ្ធភាពនូវការថែរក្សាសុខភាព ដែលមានគុណភាព និងដែលអាចទទួលប្រើបាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។

៥-ក្រុមជនងាយរងគ្រោះពិសេស រួមមានក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬជំងឺរបេង ។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រ

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដោយអនុលោមតាមច្បាប់ស្ដីពីមាត្រាសាស្ត្រកម្ពុជា។ សេចក្ដីព្រាងអនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម៖



-ធានាឱ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌ និងត្រឹមត្រូវ
-បង្កឱ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រមានភាពត្រឹមត្រូវ
-ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ផលិតផលទំនិញ និងសេវាកម្ម
-ធានាធ្វើឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងគុណភាពទំនិញ ផលិតផល និងសេវាកម្ម
-កំណត់អត្តសញ្ញាណ និងលុបបំបាត់របាំងបច្ចេកទេស ដើម្បីឱ្យមានសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្មលើវិស័យនីត្យានុកូលភាពមាត្រាសាស្ត្រ
-ធ្វើឱ្យមានជំនឿ និងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រា សាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន
-សម្រួលការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ច[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្ដីព្រាងនេះ ហើយបានសម្រេច កែសម្រួលទម្រង់ ខ្លឹមសារពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្ដីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះទាំងស្រុង៕

[១] អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុស្ដីពី សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រ។

## កិច្ចប្រជុំឡើងវិញលើ៖

### សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតកាយរឹទ្ធិជាតិកម្ពុជា

### និងសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋានកាយរឹទ្ធិជាតិកម្ពុជា

កាលពីថ្ងៃទី២៧ ខែតុលា និងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:00នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **អ៊ុក ឡូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើកិច្ចប្រជុំឡើងវិញលើ សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតកាយរឹទ្ធិជាតិកម្ពុជា និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរឹទ្ធិជាតិកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងសមាគមន៍ជាតិកាយរឹទ្ធិកម្ពុជា សមាជិក និង អគ្គលេខាធិការរងនៃក.ស.វ. សមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





គួររំឭកថា សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតកាយរឹទ្ធិជាតិកម្ពុជា និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានកាយរឹទ្ធិជាតិកម្ពុជា បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេសម្តងរួចមកហើយ គឺនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ ហើយអង្គប្រជុំនាពេលនោះ បានសម្រេចបង្កើតក្រុមការងារបង្កៀត ដើម្បីរៀបចំសេចក្តីព្រាងទាំងនោះឡើងវិញ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្លាស់ប្តូរយោបល់លើសេចក្តីព្រាងអនុក្រឹត្យកែសម្រួលថ្មីនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគយ៉ាងច្រើន ដើម្បីឱ្យសេចក្តីព្រាងទាំងនេះមានលក្ខណៈគ្រប់គ្រាន់។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ២០១០



កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាពឯកឧត្តម **ទី យ៉ាវ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែកញ្ញា ឆ្នាំ២០១០** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➢ *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងខែកញ្ញាឆ្នាំ២០១០នេះ កើនឡើង 0.៧% បើធៀបនឹងខែសីហា និងកើនឡើង ១.៩% ក្នុងរយៈពេល១២ខែ។* ក្នុងនោះក្រុមម្ហូបអាហាររួមចំណែក ៦៥% ទៅលើការកើនឡើងនៃសន្ទស្សន៍ថ្លៃសរុបនាខែនេះ និងក្រៅពីនោះ ក្រុមសំលៀកបំពាក់ និងស្បែកជើង រួមចំណែក ៤% ភោជនីយដ្ឋាន ១៥% ការដឹកជញ្ជូន ១១.៣% សាំងមួយមុខរួមចំណែក ១0% និងទូរគមនាគមន៍ ៨%។

➢ *កំណើនសន្ទស្សន៍ថ្លៃក្នុងខែកញ្ញានេះ ធ្វើឲ្យសន្ទស្សន៍ថ្លៃមធ្យមនៃទំនិញប្រើប្រាស់គ្រប់មុខ កើនឡើង ៤.២% បើប្រៀបធៀបរយៈពេល ៩ ខែដូចគ្នា ឆ្នាំ ២០១០/២00៩។*

➢ បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ (កញ្ញា/សីហា) បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ▪ ម្ហូបអាហារ: +១.១% (+២.៤% )<br>▪ សំលៀកបំពាក់ និងស្បែកជើង: +១% (+0.២%)<br>▪ គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់: +0.៤% (–0.៧% )<br>▪ សុខាភិបាល: +0.៥% (–១.៨%)<br>▪ ការដឹកជញ្ជូន: +0.៧% (+២.៨%)<br>▪ ទូរគមនាគមន៍: +៥.៧% (+0.៣%)<br>▪ ការកំសាន្ត និងវប្បធម៌: +0.៨% (+0.៦%)<br>▪ ភោជនីយដ្ឋាន: +១.៩% (+១.១%)<br>▪ ទំនិញ និងសេវាកម្មផ្សេងទៀត: +0.៩% (+៩.៩%) | ▪ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: –0.៧% (–0.២%)<br>▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត: –១% (+២.១%) |

តារាងខាងក្រោមបង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងអំឡុង៣ឆ្នាំចុងក្រោយ។ និន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃនេះក្នុងឆមាសទី២ ឆ្នាំ២០១០នេះ មាននិន្នាការកើនឡើង។

| ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១០ | 0.0% | 0.៣% | 0.៦% | -0.៣% | 0.២% | 0.0% | 0.៥% | 0.៩% | 0.៧% | – | – | – | – |
| ២00៩ | -១.៥% | -0.១% | ១.៣% | ១.0% | ១.0% | ១.៩% | ១.៤% | 0.៧% | 0.៥% | -0.៣% | -0.៦% | -0.១% | -0.៧% |
| ២00៨ | ១.៨% | -0.៥% | ៨.៣% | ៤.៤% | ២.៩% | 0.៩% | 0.៥% | -0.៣% | -0.១% | -១.១% | -៣.៤% | -៣.៩% | ២៥% |

➢ ក្នុងខែកញ្ញាឆ្នាំ២០១០នេះ អត្រាប្តូរប្រាក់ **៛/ដុល្លារ** ស្មើនឹង **៤,២២៧៛/១ដុល្លារ** បើធៀបនឹងខែមុន ប្រាក់រៀល ឡើងថ្លៃ 0.២% ធៀបនឹងដុល្លារ ប៉ុន្តែចុះថោក ១.៣% ក្នុងរយៈពេល១២ខែ ។

➢ អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣៩៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក ៣% ធៀបនឹងបាត និងចុះថោក ១២% ក្នុងរយៈពេល១២ខែ។

➢ អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **0.២១៧៛/១ដុង** បើធៀបនឹងខែមុន អត្រានេះស្ថិតនៅស្ថិរ ប៉ុន្តែប្រាក់រៀលឡើងថ្លៃ ៦.៥% ធៀបនឹងដុង ក្នុងរយៈពេល១២ខែ។

## ២) ស្ថានភាពថវិកាជាតិ

➢ *យោងតាមស្ថិតិដែលឆ្លងកាត់តែនាគារជាតិ **ចំណូលថវិកាជាតិ**ក្នុងខែកញ្ញាឆ្នាំ២០១០នេះ **អនុវត្តបានចំនួន ៤៥០.៣ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៧២% នៃគម្រោង) ក្នុងនោះ **ចំណូលមូលធន ២.៣ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ១០% នៃគម្រោង) និង**ចំណូលចរន្ត ៤៤៨.0 ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៩៨% នៃគម្រោង)* ។

➢ *បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ**ខែកញ្ញា ថយចុះ៣.៣% ប៉ុន្តែកើនឡើង ១៧% ក្នុងរយៈពេល១២ខែ* ។ **ការថយចុះ**នាខែនេះ គឺបណ្តាលមកពីចំណូលមូលធន *ថយចុះ៤២%* និងចំណូលចរន្ត*ថយចុះ៣%* ។

- ក្នុងចំណូលចរន្តនាខែកញ្ញា ចំណូលសារពើពន្ធ*ថយចុះ0.៩%* និងចំណូលមិនមែនសារពើពន្ធ*ថយចុះ១៦%* ។

| ក្នុងចំណូលសារពើពន្ធ | ក្នុងចំណូលមិនមែនសារពើពន្ធ |
|---|---|
| ✓ ពន្ធ និងអាករគយ*កើនឡើង ២.៩%* | ✓ នេសាទ កើនឡើង ៨0% |
| ✓ ចំណូលពន្ធដារ*កើនឡើង ៤.៨%* | ✓ វុក្ខាប្រមាញ់ថយចុះ ២៧% |
| ✓ ចំណូលសារពើពន្ធផ្សេងៗ*ថយចុះ ២៣%* | ✓សម្បទានរ៉ែ កើនឡើង ៣៣៣% |
| | ✓ អាកាសចរណ៍ស៊ីវិលថយចុះ ៨៧% |
| | ✓ ផលទុនទេសចរណ៍ កើនឡើង ១៣% |
| | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ កើនឡើង ១.៩% |
| | ✓ អាករស្ថានទូត ថយចុះ ៩.៥% |
| | ✓ ការត្រួតពិនិត្យគុណភាពផលិតផល ថយចុះ ៦៤% |
| | ✓ ជួលរោងចក្រ សហគ្រាសថយចុះ ១.៨% |
| | ✓ ឯកជនភាវូបនីយកម្ម កើនឡើង ១0១៥% |
| | ✓ ការលក់អចលនកម្ម កើនឡើង ៩២% |

➢ ***ចំណាយថវិកាជាតិ*** នៅខែកញ្ញា ឆ្នាំ២០១០នេះ អនុវត្តបាន **៦៦៩.៤ពាន់លានរៀល** (ជាមធ្យមប្រចាំខែ ស្មើនឹង ៧0%នៃគម្រោង) ក្នុងនោះ **ចំណាយចរន្ត ៥២៤.៥ពាន់លានរៀល** (ជាមធ្យមប្រចាំខែ: ៩២%នៃគម្រោង) និង**ចំណាយមូលធន ១៤៤.៩ពាន់លានរៀល** (ជាមធ្យមប្រចាំខែ: ៣៦%នៃគម្រោង)។

➢ *បើធៀបនឹងខែមុន **ចំណាយថវិកាជាតិកើនឡើង** ៦.១% និងកើនឡើង ៥២% ក្នុងរយៈពេល១២ខែ* ។ ការកើនឡើងចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្ត*កើនឡើង ១៨%* ។ ចំណែកឯចំណាយមូលធន*ថយចុះ២២%* ។

➢ ***តុល្យភាពថវិកាជាតិក្នុងខែកញ្ញានេះមានឱនភាពចំនួន ២១៩ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុ

➢ ក្នុងខែកញ្ញាឆ្នាំ ២០១០ **រូបិយវត្ថុ** $M_2$ មានចំនួន ***១៨,៨៤៨ពាន់លានរៀល*** កើនឡើង១.១% ធៀបនឹងខែមុន និងកើនឡើង ២៧% ក្នុងរយៈពេល១២ខែ។ ការកើនឡើងនៃ $M_2$ នាខែនេះបណ្តាលមកពីការកើនឡើងនូវ រូបិយវត្ថុក្រៅធនាគារ 0.៣% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ៦.២% និងប្រាក់បញ្ញើជារូបិយបណ្ណ ១.៤%។ គួរចាប់អារម្មណ៍ថា មានការថយចុះនៃប្រាក់បញ្ញើចរន្តនាខែនេះ *២៧%*។

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែកញ្ញាឆ្នាំ ២០១០នេះ មានចំនួន**២,៤៩៦ លានដុល្លារ** *កើនឡើង ៦%* ធៀបនឹងខែមុន និងកើនឡើង ១៥% ក្នុងរយៈពេល១២ខែ។

➢ ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែកញ្ញា ឆ្នាំ២០១០ មានចំនួន **២,១២0ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧0ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៣៩១ ពាន់លានរៀល**។

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែសីហាឆ្នាំ ២០១០នេះ មានចំនួន**២,៣៥៥ លានដុល្លារ** *កើនឡើង ០.២%* ធៀបនឹងខែមុន និង កើនឡើង ៩% ក្នុងរយៈពេល១២ខែ។

➢ ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែសីហាឆ្នាំ ២០១០ មានចំនួន **២,៦៧៧ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧០ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៤០៦ពាន់លានរៀល**។

➢ *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែសីហាឆ្នាំ ២០១០នេះ មានចំនួន **៧,៦៣០ ពាន់លានរៀល** កើនឡើង ៤.៣% បើធៀបនឹងខែមុន និងកើនឡើង ៣១% ក្នុងរយៈពេល ១២ខែ។

➢ *ការផ្តល់ឥណទានដោយធនាគារពាណិជ្ជជារួមមានការកើនឡើងជាលំដាប់* ឯក្នុងខែសីហានេះមានចំនួន ១២,៣០១ ពាន់លានរៀល កើនឡើង ១.៣% បើធៀបនឹងខែមុន និងកើនឡើង ២៣% ក្នុងរយៈពេល១២ខែ។

➢ *ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ* មានចំនួន **១,៥៥៧ ពាន់លានរៀល** កើនឡើង ៧.៤% បើធៀបនឹងខែមុន និងកើនឡើង ៣៨% ក្នុងរយៈពេល១២ខែ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារ ពាណិជ្ជទាំងអស់) ស្មើនឹង ៦.៥៨% ថយចុះ ០.៣% ធៀបនឹងខែមុន និងថយចុះ ៤.៤% ក្នុង រយៈពេល១២ខែ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជក្នុងខែសីហានេះស្មើនឹង **៤.៤៦%** ថយចុះ ១.១% ធៀបនឹងខែមុន និងថយចុះ ២៥% ក្នុងរយៈពេល១២ខែ។

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ កសិកម្ម: ខែសីហា

- ផលិតកម្មនេសាទចំនួន **៣០ ពាន់តោន** ថយចុះ ១៤% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ក្នុងរយៈពេល១២ខែ។

➢ ឧស្សាហកម្ម: ខែសីហា

- ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១,១៣២ពាន់លានរៀល (បានពី១៧៣រោងចក្រ)។
- ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៩៨.៥លានគីឡូវ៉ាត់ម៉ោង កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ១៤% ក្នុងរយៈពេល១២ខែ។

➢ សំណង់: ខែសីហា

- **សំណង់អនុញ្ញាតឲ្យសាងសង់**មានចំនួន ១៥០.៨ពាន់ម² ថយចុះ ៣៣% បើធៀបនឹងខែមុន និង ថយចុះ៩០% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ៥២.៦លានដុល្លារ ថយចុះ ៣១% បើធៀបនឹងខែមុន និងថយចុះ ៨៨% ក្នុងរយៈពេល ១២ខែ។
- **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (៥៨%នៃសំណង់អនុញ្ញាតសរុប) និងឧស្សាហកម្ម (១៦%នៃសំណង់អនុញ្ញាតសរុប)។

➢ វិនិយោគ: នាខែសីហានេះគម្រោងវិនិយោគអនុញ្ញាតិដោយ គ.វ.ក. មានចំនួន ៣។ បើគិតជា ទុនវិនិយោគ មានទឹកប្រាក់ស្មើនឹង **៩លានដុល្លារ** ថយចុះ ៩៦% បើធៀបនឹងខែមុន និងថយចុះ ៨៩% ក្នុងរយៈពេល ១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **៥.៩ ពាន់នាក់**។

➢ សេវាកម្ម និងទេសចរណ៍: ខែសីហា

- **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្មមានចំនួន ២២៤ កើនឡើង ១៣% បើធៀបនឹងខែមុន
- **ការដាក់ពាក្យរកការងារទៅក្រៅប្រទេសនៅក្រសួងការងារ**មានចំនួន ៤,០២៧នាក់ កើនឡើង ០.៨% បើធៀបនឹងខែមុន និងកើនឡើង ៦៤៩% ក្នុងរយៈពេល ១២ខែ។

– ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុងកើនឡើង ១២០% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ៣៩% ក្នុងរយៈពេល១២ខែ

–ទំនិញឆ្លងកាត់ផែភ្នំពេញថយចុះ ៦១% បើធៀបនឹងខែមុននិងថយចុះ ៥១% ក្នុងរយៈពេល១២ខែ

▪ **អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ២០៦៣ពាន់នាក់ ថយចុះ ១៩% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។

▪**ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស**មាន ៤៦ពាន់នាក់ កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ៣៣% ក្នុងរយៈពេល១២ខែ។

▪ **ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា**មាន ១៧៣ពាន់នាក់ ថយចុះ ១៦.២% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវអាកាសមាន **៨៦ពាន់នាក់** ថយចុះ ១៨% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៨% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវគោក និងទឹកមាន **៨៧ពាន់នាក់** ថយចុះ ១៤.៣% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល១២ខែ។

▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ (ទូទាំងប្រទេស) មានចំនួន**៥,៨៤៦នាក់** ថយចុះ ១៦% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៣% ក្នុងរយៈពេល១២ខែ។

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➢យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែកញ្ញា ឆ្នាំ២០១០ មានចំនួន ១,៧០៥ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៣.២% ប៉ុន្តែកើនឡើង ៥០% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ៖

| ទំនិញដែលកើនឡើង (កញ្ញា/សីហា) | ទំនិញដែលថយចុះ (កញ្ញា/សីហា) |
|---|---|
| - ប្រេងឥន្ធនៈ៖ +០.៧% | - ឧស្ម័ន៖ –៥.៦% |
| - គ្រឿងអេឡិចត្រូនិច៖ +៥៩ | - ដែកសំណង់៖ –៣៥% |
| - រថយន្តសរុប (ពាន់លានរៀល)៖ +២៩% | - ស៊ីម៉ង់៖ –១០% |
| - ម៉ូតូ៖ +២៩% | - ត្រាក់ទ័រនិងគោយន្ត៖ –១.១% |
| - ផ្លែឈើនិងបន្លែ៖ +១៩១% | - ស្រាសាលី៖ –៣៣% |
| - ជីនិងថ្នាំកសិកម្ម៖ +១១% | - អង្ករ៖ –៣៨% |
| - នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ៖ +៣៣៥% | - បារី៖ –១៣% |

➢**ការនាំចេញ** ក្នុងខែកញ្ញាឆ្នាំ២០១០ មានចំនួន ១,៣១៧ពាន់លានរៀល ថយចុះ ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៩៧% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ ការនាំចេញដែលថយចុះមានផលិតផលឈើកែច្នៃ ៩៩%ផលិតផលវាយនភណ្ឌនិងស្បែកជើង ៧.៣% កៅស៊ូ ១២%។ ការនាំចេញដែលកើនឡើងមាន អង្ករ ៣៣%និងផលិតផលនេសាទ ៨៨%។

➢ *ក្នុងខែកញ្ញាឆ្នាំ២០១០នេះជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៣៨៨ពាន់លានរៀល។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. បញ្ហាសំខាន់ៗ នៃស្មារតីអង្គប្រជុំ

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:*

១) **ការឡើងថ្លៃទំនិញ:** អតិផរណាដែលកើតមានឡើងនៅ ក្នុងប្រទេសកម្ពុជាក្នុងឆមាសទី២ ឆ្នាំ ២០១០ នេះ ជាចំបងទទួលរងឥទ្ធិពលនៃ៖

–ការឡើងថ្លៃទំនិញនៅក្នុងប្រទេសជិតខាង ដែលកម្ពុជានាំចូល (ថៃ និងវៀតណាម)

– ការឡើងថ្លៃនៃប្រាក់បាត និងការចុះថ្លៃនៃប្រាក់ដុល្លារ

– និន្នាការកើនឡើងនៃតម្រូវការក្នុងស្រុកលើទំនិញប្រើប្រាស់ ទំនិញមូលធន និងការកើនឡើងនៃតម្រូវការពិភពលោកលើម្ហូបអាហារ។

ដូច្នេះកម្ពុជា ដែលមានការពឹងផ្អែកលើការនាំចូលពីប្រទេសជិតខាង ងាយរងឥទ្ធិពល នៃបម្រែបម្រួលថ្លៃ និងអត្រាប្តូរប្រាក់ក្នុងប្រទេសទាំងនោះ។




២) ឱនភាពថវិកាជាតិ មានជាប្រចាំ និងពេលខ្លះក្នុងទំហំយ៉ាងធំ ជាសម្ពាធលើការដោះស្រាយបញ្ហាសង្គម និងហេដ្ឋារចនាសម្ព័ន្ធ។ ចំណូលថវិកាជាតិមិនសម្រេចបានតាមគំរោង ដូច្នេះប្រព័ន្ធពន្ធដារគួរត្រូវបានពិនិត្យឡើងវិញ សិក្សា និងកែលម្អ។

### ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញា ឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. សម្បទានរ៉ែ | +៣៣៣% | +៩២៧% | – |
| ២. ចំណូលពីឯកជនភាវូបនីយកម្ម | +១០១៥% | +៣០% | – |
| ៣. សំណង់អនុញ្ញាតអោយសាងសង់ (ពាន់ម២) | +៣៩៥% | +២៩៦% | –មានការការកើនឡើងនូវសំណង់សាធារណៈ លំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងផ្សេងៗ<br>–ទោះជាមានការកើនឡើងនៃផ្ទៃក្រឡា ដែលអនុញ្ញាតតម្លៃសំណង់មានការថយចុះ |
| ៤. នាំចូលផ្លែឈើ និងបន្លែ | +១៩១% | +៣៤៧% | – |
| ៥. នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣៣៥% | +៤៧% | – |
| ៨. នាំចេញអង្ករ | +៣៣% | +៤៧៣% | – |

## កំណត់សំគាល់

- ព័ត៌មាន និងទិន្នន័យពណ៌ បៃតង សំដៅលទ្ធផលល្អ

- ព័ត៌មាន និងទិន្នន័យពណ៌ ក្រហម សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អ៊ឺរ៉ុប លើកទី៨ នៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២ | ០៧/១០/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ មាតុភូមិនិវត្តន៍ជាផ្លូវការ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៣ | ១០/១០/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ស្តេចយាងនិវត្តន៍មកមាតុប្រទេសវិញ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៤ | ១១/១០/១០ ល្ងាច | ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុនសាងសង់វិស្វកម្មយូណាន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៣/១០/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលវប្បធម៌សម្តេចតេជោ **ហ៊ុន សែន** នាវិទ្យាស្ថានជាតិអប់រំ |
| ៦ | ១៣/១០/១០<br>ម៉ោង ១៥:៣០<br>ល្ងាច | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី<br>២- អនុក្រឹត្យស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត<br>៣- បញ្ហាផ្សេងៗ<br>ដើម្បីត្រៀមប្រជុំជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៣/១០/១០<br>១៩:០០ យប់ | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ក្នុងពិធីទទួលទានអាហាររៀបចំជូន ឯកឧត្តម Jean-Francois DESMAZIERES ឯកអគ្គរដ្ឋទូតបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជម្រាបលាបញ្ចប់អាណត្តិបេសកកម្ម នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១៤/១០/១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១- ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី<br>២- អនុក្រឹត្យស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត<br>៣- បញ្ហាផ្សេងៗ |
| ៩ | ១៤/១០/១០ ល្ងាច | ប្រជុំពិភាក្សាការងារជាមួយ៖<br>Mr. Louis Roch Burgard, Director of Vinci Concession<br>Mr. Nicolas Norebaert, President of Vinci Airport<br>Mr. Nicolas Deviller, CEO of SCA<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៥/១០/១០ ព្រឹក | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១<br>២- សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩<br>៣- បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ " កិច្ចព្រមព្រៀងពហុភាគីអាស៊ាន ស្តីពីសេរីភាវូបនីយកម្មពេញលេញ នៃសេវាដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវអាកាស ព្រមទាំងពិធីសារទាំង៨ "។ |
| ១១ | ១៨/១០/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតនៃសាកលវិទ្យាល័យ អាយ អាយ ស៊ី នៃវិទ្យាស្ថានបច្ចេកវិទ្យា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលវប្បធម៌ សម្តេចតេជោ **ហ៊ុន សែន** នាវិទ្យាស្ថានជាតិអប់រំ។ |
| ១២ | ១៨/១០/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី ចម្រើនព្រះបរិត្ត ឡើង**វិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៩/១០/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធ **អគារសន្តិភាព និងអគារមិត្តភាព នៃគណៈរដ្ឋមន្ត្រី** ក្រោមព្រះរាជាធិបតីភាព **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ២១/១០/១០ ព្រឹក | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១- អនុក្រឹត្យស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត<br>២- បញ្ហាផ្សេងៗ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | ២៥/១០/១០ ល្ងាច | ប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អំពីការងារបណ្តុះបណ្តាលបុគ្គលិកថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី និងសាងសង់អគារ IT នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៧/១០/១០ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរ ឯកឧត្តម Ban Ki-moon អគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅទស្សនកិច្ច នៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា។ |
| ១៧ | ២៨/១០/១០ ម៉ោង ៨:០០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី១៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៨ | ២៨/១០/១០ ម៉ោង ១០:៣០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ហុងគ្រី (HUN-DEV) និងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ៣១/១០/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មាតុភូមិនិវត្តន៍ជាផ្លូវការ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គឹម សយសាម៉ាឡៃ អនុប្រធាន ECOSOCC ប្រចាំខែតុលា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៩/១០/១០ | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធ **អគារសន្តិភាព និងអគារមិត្តភាព** នៃគណៈរដ្ឋមន្ត្រី ក្រោមព្រះរាជាធិបតីភាព **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២១/១០/១០ | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយសម្រាប់ត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើ៖<br>១- អនុក្រឹត្យស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត<br>២- បញ្ហាផ្សេងៗ |
| ៣ | ២៧/១០/១០ | ចូលរួមក្នុងកិច្ចប្រជុំផ្តល់បទបង្ហាញស្តីពី SCM របស់ប្រទេសវៀតណាម សហការជាមួយអង្គការ USAID។ |
| ៤ | ២៨/១០/១០ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ហុងគ្រី (HUN-DEV) និងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC ប្រចាំតុលា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៨/១០/១០ | ចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី ចម្រើនព្រះបរិត្ត ឡើង**វិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៩/១០/១០ | ចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធ **អគារសន្តិភាព និងអគារមិត្តភាព នៃគណៈរដ្ឋមន្ត្រី** ក្រោមព្រះរាជាធិបតីភាព **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៥/១០/១០ | ប្រជុំពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អំពីការងារបណ្តុះបណ្តាលបុគ្គលិកថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី និងសាងសង់អគារ IT នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៨/១០/១០ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ហុងគ្រី (HUN-DEV) និងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## បទបង្ហាញស្តីពី

# ការវាស់ចំណាយស្តង់ដា

# ( Standard Cost Measurement-SCM )

លោក Dr. Phan Duc Hieu អ្នកជំនាញផ្នែក Standard Cost Measurement( SCM ) មកពីវិទ្យាស្ថានកណ្តាលគ្រប់គ្រងសេដ្ឋកិច្ចនៃប្រទេសវៀតណាម ( Central Institute for Economic Management ) បានអញ្ជើញមកធ្វើបទបង្ហាញស្តីពី ការវាស់ចំណាយស្តង់ដាដែលបានអនុវត្តនៅប្រទេសវៀតណាម ជូនថ្នាក់ដឹកនាំ និងសមាជិក នៃក្រុមការងារអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ECOSOCC ) នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងមានការអញ្ជើញចូលរួម និងឧបត្ថម្ភពីអង្គការ USAID កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៩:00នាទី។





លោក Dr. Phan Duc Hieu បានបង្ហាញពីវិធីសាស្ត្រនៃការគណនាការចំណាយរបស់ទីភ្នាក់ងាររដ្ឋាភិបាល ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដូចជាការចំណាយលើការរៀបចំសេចក្តីព្រាង ការចំណាយលើការអនុម័ត ការចំណាយលើការពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តជាដើម និងការចំណាយរបស់វិស័យឯកជនក្នុងការប្រតិបត្តិតាមលិខិតបទដ្ឋានគតិយុត្ត ដូចជាការចំណាយលើការបង់កម្រៃសេវាផ្សេងៗ ការចំណាយលើការបំពាក់ឧបករណ៍ផ្សេងៗ ការចំណាយរដ្ឋបាល និងការចំណាយឱកាស។ ការចំណាយទាំងអស់នោះត្រូវបានគណនាចេញជាទឹកប្រាក់ លើកលែងតែចំណាយឱកាសដែលមិនអាចគណនាចេញជាទឹកប្រាក់បាន។ ព័ត៌មានទាំងនេះមានសារៈសំខាន់ណាស់ ចំពោះអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីទទួលបានការចំណាយតិច និងមានគុណភាពខ្ពស់។

លោក Dr. Phan Duc Hieu បានលើកឡើងពីបទពិសោធនៅប្រទេសវៀតណាមចំពោះការប្រើប្រាស់ SCM ក្នុងការវាស់វែងផលប៉ះពាល់ក្នុងកំណែទម្រង់លិខិតបទដ្ឋានគតិយុត្តនៃគម្រោងលេខ៣0 ដែលមានគោលដៅកាត់បន្ថយចំណាយប្រតិបត្តិតាមលិខិតបទដ្ឋានគតិយុត្ត ចំនួន៣0% ប្រកបដោយជោគជ័យ ៕

# ព្រឹត្តិបត្រព័ត៌មាន


| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម [illegible] | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | ឯកឧត្តម [illegible] | សមាជិកបម្រុង ក.ស.វ. |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| ប្រមូលព័ត៌មាន និងថតរូប ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក [illegible] | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasnaarrow@gmail.com